លេខ ២២ ចេញផ្សាយថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៣

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែមីនា ឆ្នាំ២០២៣

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## កិច្ចប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន Stronghold Trustee Co., Ltd.

នាព្រឹកថ្ងៃពុធ ១០កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១ ខែមីនា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **លោក ហាយ សុវណ្ណា** ប្រធានស្តីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច និងសហការី បានទទួលស្វាគមន៍ និងជួបពិភាក្សាការងារជាមួយ **លោកស្រី Carol Lau** តំណាងក្រុមហ៊ុន Pacific Founder ដែលមានទីស្នាក់ការធុរកិច្ចនៅប្រទេសសិង្ហបុរី និងមានធុរកិច្ចពាក់ព័ន្ធនឹងបរធនបាលកិច្ច និងបច្ចេកវិទ្យាហិរញ្ញវត្ថុ និង **លោក Hans Chen** នាយកប្រតិបត្តិនៃក្រុមហ៊ុន Stronghold Trustee Co., Ltd.។ កិច្ចប្រជុំនេះ បានផ្តោតជាសំខាន់ទៅលើឧត្តមានុវត្តន៍ កាលានុវត្តន៍ភាព និងគំនិតផ្តួចផ្តើមមួយចំនួនក្នុងការចូលរួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅកម្ពុជា។



រូបភាពកិច្ចកិច្ចប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន Stronghold Trustee Co., Ltd.។

## មាតិកា


- កិច្ចប្រជុំពិភាក្សាការងារជាមួយក្រុមហ៊ុន Stronghold Trustee Co., Ltd. ទំព័រទី១
- សិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពី "វិធានក្នុងការគ្រប់គ្រងការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" ទំព័រទី២
- សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ទំព័រទី២
- កម្មវិធីការងារសង្គម នៅមណ្ឌល "បូរីកុមារកំព្រាបាត់ដំបង" ទំព័រទី៣
- សិក្ខាសាលាស្តីពី "បរធនបាលកិច្ច៖ រចនាសម្ព័ន្ធនៃការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិសាជីវកម្ម និងគ្រួសារ" ទំព័រទី៣
- កម្មវិធីសំណេះសំណាលលើកទឹកចិត្ត និងលើកកម្ពស់មន្ត្រីជានារីក្នុងឱកាសអបអរសាទរទិវានារីអន្តរជាតិ ៨ មីនា ទំព័រទី៤
- កិច្ចប្រជុំពិភាក្សាជាមួយទីប្រឹក្សាធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ទំព័រទី៤
- កម្មវិធី "វគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចលើកទី២" ទំព័រទី៤
- កិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីសេចក្តីព្រាងវិធានការគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុមិនមែនធនាគារ ទំព័រទី៥
- កម្មវិធីកិច្ចពិភាក្សា៖ បទពិសោធន៍អនុវត្តន៍ បញ្ហាប្រឈម និងកាលានុវត្តភាព ទំព័រទី៥
- កម្មវិធីកាត់កញ្ចប់វិញ្ញាសារប្រឡង និងប្រកាសបើកកម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី២ ឆ្នាំ២០២៣ ទំព័រទី៦
- សិក្ខាសាលាផ្សព្វផ្សាយ និងបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី "ដំណើរការ និងនីតិវិធីក្នុងការទទួលបានឥណទានក្រោមគម្រោង ACSEP សមាសភាគទី១" ទំព័រទី៦
- ពិធីប្រកាសដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ឆ្នាំ២០២៣-២០២៧ "គណនេយ្យភាពសមិទ្ធកម្ម" ទំព័រទី៧
- សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ទំព័រទី៨
- បេសកកម្មត្រួតពិនិត្យជាក់ស្តែងដល់ការដ្ឋានស្ថាបនាផ្លូវមួយខ្សែក្រោម MRD-PIU3 ប្រវែង ១២.៥ គីឡូម៉ែត្រ ទំព័រទី៨
- កិច្ចជំនួបដើម្បីចែករំលែកពីវឌ្ឍនភាពនៃកិច្ចដំណើរការអភិវឌ្ឍន៍នៃវិស័យបរធនបាលកិច្ច ទំព័រទី៩
- បេសកកម្មត្រួតពិនិត្យជាក់ស្តែងដល់ការដ្ឋានស្ថាបនាផ្លូវមួយខ្សែក្រោម MRD-PIU3 ប្រវែង ១៧.៥ គីឡូម៉ែត្រ ទំព័រទី៩
- ពិធី "ប្រកាសពង្រីកការប្រើប្រាស់មុខងាររបស់ប្រព័ន្ធ FMIS, ការអនុវត្តនីតិវិធីតាមប្រព័ន្ធ FMIS ទាំងស្រុង, ការប្រើប្រាស់ប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី ១ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង ការដាក់ឱ្យអនុវត្តគម្រោងរៀបចំមុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅក្រសួងចំនួន ៥ដំបូង" ទំព័រទី១០
- កិច្ចពិភាក្សាការងារជាមួយក្រុមប្រតិភូរបស់ក្រុមហ៊ុន Phillip Capital Group ទំព័រទី១០
- ពិធីចុះហត្ថលេខាលើកិច្ចសន្យា Trust Deed រវាងក្រុមហ៊ុន បេនចារ៉ាន អ៊ែរសេត មេនេចមិន (ខេមបូឌា) ម.ក និងក្រុមហ៊ុន ស្តេងហ្វូល ត្រាសធី ឯ.ក ទំព័រទី១១
- កិច្ចប្រជុំដើម្បីត្រៀមបើកដាក់ឱ្យដំណើរការកម្មវិធីសវនកម្មឆ្នាំ២០២៣ ទំព័រទី១១
- កិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ទំព័រទី១១
- សិក្ខាសាលាផ្សព្វផ្សាយ និងបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី "ដំណើរការ និងនីតិវិធីក្នុងការទទួលបានឥណទានក្រោមគម្រោង ACSEP សមាសភាគទី១" ទំព័រទី១២
- ពិធី "សម្ពោធអគារសិក្សាថ្មី នៅសាលាបឋមសិក្សា ជោគជ័យ" ទំព័រទី១៣




អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## សិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច"

នាព្រឹកថ្ងៃសុក្រ ១២កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)** និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានសហការជាមួយរដ្ឋបាលខេត្តបន្ទាយ-មានជ័យ ដើម្បីរៀបចំសិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" នៅ ដឺវ៉ាយ ផាលេស រីសត ខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និង **លោក ហ៊ឹល វ៉ាយ៉ា** អភិបាលរងនៃគណៈអភិបាលខេត្តបន្ទាយ-មានជ័យ តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អ៊ុំ រាត្រី** អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ។

សិក្ខាសាលាផ្សព្វផ្សាយនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងបន្ថែមឱ្យបានកាន់តែទូលំទូលាយដល់សាធារណជន ក៏ដូចជាភាគីពាក់ព័ន្ធដទៃទៀត ថាអ្វីជាបរធន-បាលកិច្ច? បរធនបាលកិច្ចមានយន្តការ និងប្រតិបត្តិការដូចម្តេច? ធ្វើដូចម្តេចទើបការបង្កើត និងចុះបញ្ជីបរធនបាលកិច្ចមានភាពត្រឹមត្រូវ និងមានអនុលោមភាពតាមច្បាប់? សិក្ខាសាលាផ្សព្វផ្សាយនេះ ក៏បានរំលេចផងដែរអំពីតួនាទី និងសារសំខាន់របស់យន្តការបរធន-បាលកិច្ចក្នុងការបង្កើត និងចុះបញ្ជី និងបង្កើតទំនុកចិត្ត ក៏ដូចជាទាក់ទាញការវិនិយោគបន្ថែម ជាពិសេសចូលរួមចំណែកជំរុញដំណើរការអភិវឌ្ឍន៍គម្រោងធុរកិច្ចនានាក្នុងខេត្តបន្ទាយមានជ័យផងដែរ ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

សិក្ខាសាលាផ្សព្វផ្សាយនេះ ក៏មានអ្នកចូលរួមសរុបប្រហែល ១០០ រូប ផងដែរ ដែលជាថ្នាក់ដឹកនាំ និងតំណាងអញ្ជើញមកពីស្ថាប័ន មន្ទីរ និងអង្គភាពនានានៃរដ្ឋបាលខេត្តបន្ទាយមានជ័យ, សមាជិក-សមាជិកានៃសភាពាណិជ្ជកម្ម, សម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា, ស៊ីអ៊ីអូ ម៉ាស្ទ័រ ក្លឹប និងសមាគមធុរកិច្ចពាក់ព័ន្ធ ព្រមទាំងតំណាងក្រុមហ៊ុនបរធនបាល, ធនាគារពាណិជ្ជដែលជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាពឬសេវារក្សាទុក, បរធនបាល, ក្រុមហ៊ុនវាយតម្លៃក្នុងវិស័យបរធនបាលកិច្ច និងរូបវន្តបុគ្គលឯករាជ្យ ដែលទទួលបានអាជ្ញាបណ្ណ ការអនុញ្ញាត និងការទទួលស្គាល់ពីនិយ័តករបរធនបាលកិច្ច។



រូបភាពសិក្ខាសាលាផ្សព្វផ្សាយអំពីប្រកាសស្តីពី "វិធានក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**។

## សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

នាព្រឹកថ្ងៃសៅរ៍ ១៣កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៣ និយ័តករបរធន-បាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យជាតិបាត់ដំបង បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច និង **លោក ទេព នារ៉ា** សាកលវិទ្យាធិការរងនៃសាកលវិទ្យាល័យជាតិបាត់ដំបង នៅសាកលវិទ្យាល័យជាតិបាត់ដំបង។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។

កម្មវិធីនេះមានការអញ្ជើញចូលរួមពី **ឯកឧត្តម ឈុន សម្បត្តិ** ប្រធានអង្គភាពសវនកម្មផ្ទៃក្នុង នៃ **អ.ស.ហ.** ជាអធិបតី អមដោយសហការី, ថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យជាតិបាត់ដំបង ដែលមានចំនួនសរុបប្រមាណ ១៨០ រូប។ កម្មវិធីត្រូវបានបញ្ចប់ទៅដោយភាពរលូន និងប្រកបដោយផ្លែផ្កា ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល។



រូបភាពសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**។

## កម្មវិធីការងារសង្គម នៅមណ្ឌល "បូរីកុមារកំព្រាបាត់ដំបង"

នារសៀលថ្ងៃសៅរ៍ ១៣កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំកម្មវិធីការងារសង្គម នៅមណ្ឌល "បូរីកុមារកំព្រាបាត់ដំបង" ខេត្តបាត់ដំបង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច និងលោកជំទាវ រួមដំណើរជាមួយ **ឯកឧត្តម ឈុន សម្បត្តិ** ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ **ឯកឧត្តម នង ពិសិដ្ឋ ឯកឧត្តម ណឹ សាកល** អគ្គនាយករងនៃ **ន.ប.ធ.** និងសហការី ដោយបានពាំនាំយកនូវអំណោយសប្បុរសធម៌ជាគ្រឿងឧបភោគបរិភោគ និងសម្ភារៈមួយចំនួនដូចជា៖ សម្ភារៈសិក្សា សៀវភៅអាន ថ្នាំពេទ្យនិងប្រអប់សង្គ្រោះបឋម អាល់កុល សាប៊ូ ប្រាសនិងថ្នាំដុសធ្មេញ អង្ករ មី ត្រីងៀត ត្រីខ ភេសជ្ជៈ ព្រមទាំងគ្រឿងឧបភោគបរិភោគផ្សេងៗទៀត ក៏ដូចជាអាហារសម្រន់ ផងដែរ ដើម្បីចែកជូនប្អូនៗកុមារ និងមន្ត្រីបម្រើការងារនៅក្នុងមណ្ឌល។

នាឱកាសនេះដែរ **ឯកឧត្តម សុខ ដារ៉ា** ក៏បានសម្តែងការកោតសរសើរ ក៏ដូចជាផ្តល់អនុសាសន៍លើកទឹកចិត្ត និងចែករំលែកបទពិសោធន៍ជីវិតដល់ប្អូនៗកុមារ ឱ្យខិតខំសិក្សា និងតស៊ូប្រឹងប្រែងដើម្បីអនាគតរបស់ខ្លួន និងដើម្បីក្លាយជាទំពាំងស្នងឫស្សីដ៏រឹងមាំរបស់សង្គមនាពេលអនាគត។

កម្មវិធីការងារសង្គមនេះត្រូវបានបញ្ចប់ដោយរលូន ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល ពោរពេញទៅដោយក្តីស្រលាញ់។



រូបភាពកម្មវិធីការងារសង្គម នៅមណ្ឌល "បូរីកុមារកំព្រាបាត់ដំបង" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច។

## សិក្ខាសាលាស្តីពី "បរធនបាលកិច្ច៖ រចនាសម្ព័ន្ធនៃការគ្រប់គ្រង ចាត់ចែងទ្រព្យសម្បត្តិសាជីវកម្ម និងគ្រួសារ"

នាព្រឹកថ្ងៃអង្គារ ១រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ **កញ្ញា ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច និងមន្ត្រីជំនាញ បានចូលរួមបើកកម្មវិធីសិក្ខាសាលាស្តីពី "បរធនបាលកិច្ច៖ រចនាសម្ព័ន្ធនៃការគ្រប់គ្រង ចាត់ចែងទ្រព្យសម្បត្តិសាជីវកម្ម និងគ្រួសារ" និងចូលរួមជាវាគ្មិន ក្រោមប្រធានបទស្តីពី "ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ចក្នុងក្របខណ្ឌច្បាប់នៃព្រះរាជាណាចក្រកម្ពុជា" ព្រមទាំងចូលរួមជាវាគ្មិនក្នុងកិច្ចពិភាក្សា ក្រោមការរៀបចំដោយការិយាល័យមេធាវី DFDL នៅសណ្ឋាគារឡឺរ៉ូយ៉ាល់ ភ្នំពេញ។



រូបភាពសិក្ខាសាលាស្ដីពី "បរធនបាលកិច្ច៖ វចនាសម្ព័ន្ធនៃការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិសាជីវកម្ម និងគ្រួសារ"

## កម្មវិធីសំណេះសំណាលលើកទឹកចិត្ត និងលើកកម្ពស់មន្ត្រីជានារី ក្នុងឱកាសអបអរសាទរទិវានារីអន្តរជាតិ ៨ មីនា

នារសៀលថ្ងៃអង្គារ ១រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៣ និយ័តករបរធន-បាលកិច្ច (**ន.ប.ធ.**) បានរៀបចំកម្មវិធីសំណេះសំណាលលើកទឹកចិត្ត និងលើកកម្ពស់មន្ត្រីជានារី ក្នុងឱកាសអបអរសាទរទិវានារីអន្តរជាតិ ៨ មីនា គ.ស.២០២៣ ខួបលើកទី១១២ ក្រោមប្រធានបទ "ស្ត្រីរួមគ្នារក្សាសុខសន្តិភាព ដើម្បីកិច្ចអភិវឌ្ឍក្នុងយុគសម័យឌីជីថល" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយថ្នាក់ដឹកនាំ និងមន្ត្រីជានារីរបស់ **ន.ប.ធ.** ទាំងអស់ផងដែរ។



រូបភាពកម្មវិធីសំណេះសំណាលលើកទឹកចិត្ត និងលើកកម្ពស់មន្ត្រីជានារី ក្នុងឱកាសអបអរសាទរទិវានារីអន្តរជាតិ ៨ មីនា។

## កិច្ចប្រជុំពិភាក្សាជាមួយទីប្រឹក្សាធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

ព្រឹកថ្ងៃព្រហស្បតិ៍ ៣រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៣ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ណី សាកល** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយ **លោក ហាយ សុវណ្ណា** ប្រធានស្ដីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច បានចូលរួមកិច្ចប្រជុំពិភាក្សាជាមួយទីប្រឹក្សាធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងក្រុមការងារបច្ចេកទេសដែលជាសេនាធិការឱ្យក្រុមការងាររៀបចំសេចក្ដីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ដើម្បីពិនិត្យ និងពិភាក្សាលើលទ្ធផលនៃការសិក្សារបស់ទីប្រឹក្សា ADB លើការរៀបចំសេចក្ដី-ព្រាងគោលនយោបាយនេះ។ កិច្ចប្រជុំពិភាក្សានេះ ត្រូវបានរៀបចំឡើងនៅទីស្ដីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



រូបភាពកិច្ចប្រជុំពិភាក្សាជាមួយទីប្រឹក្សាធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។

## កម្មវិធី "វគ្គបណ្ដុះបណ្ដាល និងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចលើកទី២"

នាព្រឹកថ្ងៃចន្ទ ៧រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញប្រកាសបើក "វគ្គបណ្ដុះបណ្ដាល និងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចលើកទី២" ដែលរៀបចំដោយនិយ័តករបរធនបាលកិច្ចនៅអគារមជ្ឈមណ្ឌលអភិវឌ្ឍន៍ធុរកិច្ច។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

វគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចលើកទី២ នេះ ត្រូវបានរៀបចំរយៈពេលចំនួន ៣ ថ្ងៃ ពេញ ចាប់ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ និងមានអ្នកចូលរួមសរុបចំនួន ២១០ រូប ដែលមានសមាសភាពអញ្ជើញមកពីក្រុមហ៊ុន និងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច, បុគ្គលដែលមានបំណងផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច, និងសាធារណជន។







រូបភាពកម្មវិធី "វគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចលើកទី២" ដែលប្រព្រឹត្តិទៅកាលពីថ្ងៃទី១៣-១៦ ខែមីនា ឆ្នាំ២០២៣។

## កិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីសេចក្តីព្រាងវិធានការគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុមិនមែនធនាគារ

រសៀលថ្ងៃចន្ទ ៧រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីសេចក្តីព្រាងវិធានការគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុមិន-មែនធនាគារ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់ រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អ.ស.ហ.** និងជាប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ តាមប្រព័ន្ធ Zoom។

កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពី ឯកឧត្តមប្រតិភូ-រាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃនិយ័តករមូលបត្រកម្ពុជា និងឯកឧត្តម លោក លោកស្រីតំណាងនិយ័តករក្រោមឱវាទ **អ.ស.ហ.** ដែលជាសមាជិក សមាជិកា ក្រុមការងារបច្ចេកទេសជាសេនាធិការឱ្យក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុមិនមែនធនាគារ។




រូបភាពកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីសេចក្តីព្រាងវិធានការគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គ-លេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.**។

## កម្មវិធីកិច្ចពិភាក្សា៖ បទពិសោធន៍អនុវត្តន៍ បញ្ហាប្រឈម និងកាលានុវត្តភាព

កាលពីរសៀលថ្ងៃពុធ ៩ រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមធ្វើជាវាគ្មិនកិត្តិយសក្នុងកម្មវិធីកិច្ចពិភាក្សា៖ បទ-ពិសោធន៍អនុវត្តន៍ បញ្ហាប្រឈម និងកាលានុវត្តភាព នៃកម្មវិធីវគ្គបណ្តុះបណ្តាល និងការប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ចលើកទី២ ឆ្នាំ២០២៣ នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច ជាន់ទី១៥។

កិច្ចពិភាក្សានេះ មានការអញ្ជើញចូលរួមដោយវាគ្មិនកិត្តិយសដែលសុទ្ធសឹងជាអ្នកជំនាញក្នុងវិស័យបរធនបាលកិច្ច, វិស័យហិរញ្ញវត្ថុ និងវិស័យច្បាប់ រួមមាន៖ **លោកស្រី ខេម វណ្ណសុខ** អនុប្រធានផ្នែកប្រតិបត្តិ សាជីវកម្មនិងពាណិជ្ជកម្មនៃក្រុមហ៊ុន ឌី-អេហ្វឌីអិល ខេមបូឌា ជាអ្នកសម្របសម្រួលក្នុងកិច្ចពិភាក្សា, **លោក ប៊ុន យូឌី** មេធាវីនៃការិយាល័យមេធាវី ប៊ុន និងសហការី, **លោក LEE YI-HUNG** ប្រធានផ្នែកព័ត៌មាន និងប្រតិបត្តិការបរធនបាល នៃក្រុមហ៊ុន ដឹ ហ្វីស ឆាយណា អ៊ិន វេសមេន ត្រាស ឯ.ក, **លោក CHAN HAN-EN** នាយកប្រតិបត្តិ នៃក្រុមហ៊ុន ស្រ្តងហូល ត្រាសធី ឯ.ក, និង **លោក ហេង ឆាយ** នាយកគ្រប់គ្រងនៃការិយាល័យមេធាវី អ អេន ធី សុខ អេន ហេង។

នៅក្នុងកិច្ចពិភាក្សានេះ វាគ្មិនកិត្តិយស បានធ្វើការចែករំលែកអំពីបទពិសោធន៍ក្នុងការគ្រប់គ្រង និងចាត់ចែងបរធនបាលកិច្ច អត្ថប្រយោជន៍នៃការបង្កើតវិស័យបរធនបាលកិច្ច និងបញ្ហាប្រឈមដែលធ្លាប់បានជួបប្រទះក្នុងការអនុវត្តការងារកន្លងមក ព្រមទាំងបានចែករំលែកអំពីទស្សនវិស័យអំពីវិស័យបរធនបាលកិច្ចផងដែរ។




រូបភាពកម្មវិធីកិច្ចពិភាក្សា៖ បទពិសោធន៍អនុវត្តន៍ បញ្ហាប្រឈម និងកាលានុវត្តភាពក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** ។

## កម្មវិធីកាត់កញ្ចប់វិញ្ញាសារប្រឡង និងប្រកាសបើកកម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី២ ឆ្នាំ២០២៣

នាព្រឹកថ្ងៃព្រហស្បតិ៍ ១០រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អមដោយ **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងសហការី បានអញ្ជើញចូលរួមកាត់កញ្ចប់វិញ្ញាសារប្រឡង និងប្រកាសបើកកម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី២ ឆ្នាំ២០២៣ នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច ជាន់ទី១៥។ ការប្រឡងនេះបានបញ្ចប់ទៅដោយរលូន និងជោគជ័យ។





រូបភាពកម្មវិធីកាត់កញ្ចប់វិញ្ញាសារប្រឡង និងប្រកាសបើកកម្មវិធីប្រឡងគុណវុឌ្ឍិក្នុងវិស័យបរធនបាលកិច្ច លើកទី២ ឆ្នាំ២០២៣។

## សិក្ខាសាលាផ្សព្វផ្សាយ និងបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី "ដំណើរការ និងនីតិវិធីក្នុងការទទួលបានផលធានក្រោមគម្រោង ACSEP សមាសភាគទី១"

ថ្ងៃសុក្រ ១១រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៣ នៅក្រុងសៀមរាប ខេត្តសៀមរាប និយ័តករបរធនបាលកិច្ច (**ន.ប.ធ**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាគទី១ (PIU1) បានរៀបចំ



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

សិក្ខាសាលាផ្សព្វផ្សាយ និងបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី "ដំណើរការ និងនីតិវិធីក្នុងការទទួលបានឥណទានក្រោមគម្រោង ACSEP សមាសភាគទី១" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) និងជានាយកគម្រោង ដោយមានការចូលរួមពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោង ACSEP សមាស-ភាគទី១, **ឯកឧត្តម យុន លីនណេ** អភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប, **លោកជំទាវ មិន ធារី** អភិបាលរងនៃគណៈអភិបាលខេត្តឧត្តរមានជ័យ។

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្រោមកិច្ចសហការនិងសម្របសម្រួលពីរដ្ឋបាលខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ ក្នុងគោលបំណងផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីគម្រោង ACSEP ពាក់ព័ន្ធនឹងដំណើរការ និងនីតិវិធីក្នុងការទទួលបានឥណទានបន្ថែម ដើម្បីពង្រីក និងពង្រឹងអាជីវកម្ម ដល់សហគ្រាសកសិ-ឧស្សាហកម្ម សហគមន៍កសិកម្ម និងកសិករចិញ្ចឹមមាន់ស្រុក ជាពិសេសសហ-គ្រាសផលិត ដែលមានបំណងស្វែងរកទុនបន្ថែមសម្រាប់គាំទ្រផែនការអាជីវកម្មរបស់ខ្លួន ដោយមានអ្នកចូលរួមមកពីតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, រដ្ឋបាលមូលដ្ឋាន, ស្ថាប័នហិញ្ញវត្ថុដៃគូ, សហគ្រាសកសិ-ឧស្សាហកម្ម, សហគមន៍កសិកម្ម ក៏ដូចជាកសិករចិញ្ចឹមមាន់ ដែលអញ្ជើញមកពីខេត្តសៀមរាប និងខេត្តឧត្តរមានជ័យផងដែរ។

សូមបញ្ជាក់ថា គម្រោង ACSEP ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណង៖ ទី១).ជួយសម្រួលដល់ការទទួលបានឥណទានសម្រាប់សហគ្រាសកសិ-ឧស្សាហកម្ម និងសហគមន៍កសិកម្ម តាមរយៈធនាគារដៃគូទាំងពីរគឺ ARDB និង Sathapana ទី២).ជួយលើកកម្ពស់ទំនាក់ទំនងទីផ្សារក្នុងចំណោមសហគ្រាសកសិ-ឧស្សាហកម្ម និងសហគមន៍កសិកម្ម និងលើកកម្ពស់សុវត្ថិភាព និងគុណភាពម្ហូបអាហារ, និងទី៣).ធ្វើអោយប្រសើរឡើងនូវការតភ្ជាប់បណ្តាញផ្លូវដឹកជញ្ជូនពីកសិដ្ឋានផលិតទៅកាន់ទីផ្សារ។




រូបភាពសិក្ខាសាលាផ្សព្វផ្សាយ និងបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី "ដំណើរការ និងនីតិវិធីក្នុងការទទួលបានឥណទានក្រោមគម្រោង ACSEP សមាសភាគទី១" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) និងជានាយកគម្រោង។

## ពិធីប្រកាសដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ឆ្នាំ២០២៣-២០២៧ "គណនេយ្យភាពសមិទ្ធកម្ម"

នាព្រឹកថ្ងៃចន្ទ ១៤រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តមអគ្គនាយករង **ណី សាកល**, **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ និងមន្ត្រីជំនាញការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ បានចូលរួមក្នុងពិធីប្រកាសដាក់ឱ្យអនុវត្តកម្មវិធីកែ ទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ឆ្នាំ២០២៣-២០២៧ "គណនេយ្យភាពសមិទ្ធកម្ម" **ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នៅសណ្ឋាគារសុខាភ្នំពេញ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888







រូបភាពពិធីប្រកាសដាក់ឱ្យអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៤ ឆ្នាំ២០២៣-២០២៧ "គណនេយ្យភាពសមិទ្ធកម្ម" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

## សិក្ខាសាលាស្ដីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

នារសៀលថ្ងៃចន្ទ ១៤រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យជាតិគ្រប់គ្រងបានសហការគ្នារៀបចំសិក្ខាសាលាស្ដីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្ដម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង**ឯកឧត្ដមបណ្ឌិត ហោ ប៉េង** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យជាតិគ្រប់គ្រង នៅសាកលវិទ្យាល័យជាតិគ្រប់គ្រង។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្ដល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។

កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, ព្រឹទ្ធបុរស,សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង។ កម្មវិធីត្រូវបានបញ្ចប់ទៅដោយភាពរលូន និងប្រកបដោយផ្លែផ្កា ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល។




រូបភាពសិក្ខាសាលាស្ដីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្ដម **សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច។

## បេសកកម្មត្រួតពិនិត្យជាក់ស្ដែងដល់ការដ្ឋានស្ថាបនាផ្លូវមួយខ្សែក្រោម MRD-PIU3 ប្រវែង ១២.៨ គីឡូម៉ែត្រ

កាលពីថ្ងៃចន្ទ ១៤រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ អង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាគទី១ (PIU1) នៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ**) ដឹកនាំដោយ **លោក ប៉ុ សំអាង** ប្រធានផ្នែកប្រតិបត្តិ មន្ត្រីជំនាញសមាជិក PIU1 ទីប្រឹក្សាគម្រោង និងអ្នកជំនាញការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) តំណាងដោយ Mrs. Xin Ren និង Mrs. Indah Setyawati ដោយមានការចូលរួមពីតំណាងក្រសួងអភិវឌ្ឍន៍ជនបទ (MRD-PIU3) ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ (MRD-PIU2) អាជ្ញាធរមូលដ្ឋាននិងស្ថានប័នពាក់ព័ន្ធផ្សេងទៀត បានចុះបេសកកម្ម ត្រួតពិនិត្យជាក់ស្ដែង

ដល់ការដ្ឋានស្ថាបនាផ្លូវមួយខ្សែក្រោម MRD-PIU3 ប្រវែង ១២.៥ គីឡូម៉ែត្រ ស្ថិតនៅភូមិក្រសាំង ឃុំចុងផ្លាស់ ស្រុកតំបែរ ខេត្តត្បូងឃ្មុំ និងសហគមន៍កសិកម្មបៃតងគោកស្រុក (Beitong Korsrik Agri-Cooperative) នៅភូមិគោកស្រុក ឃុំគោកស្រុក ស្រុកគោកស្រុក ខេត្តត្បូងឃ្មុំ ដើម្បីវាយតម្លៃផលប៉ះពាល់បរិស្ថាន (ESMS) និងសុវត្ថិភាពសង្គម (safeguard)។



រូបភាពបេសកកម្មត្រួតពិនិត្យជាក់ស្តែងដល់ការដ្ឋានស្ថាបនាផ្លូវមួយខ្សែក្រោម MRD-PIU3 ប្រវែង ១២.៥ គីឡូម៉ែត្រ។

## កិច្ចជំនួបដើម្បីចែករំលែកពីវឌ្ឍនភាពនៃកិច្ចដំណើរការអភិវឌ្ឍន៍នៃវិស័យបរធនបាលកិច្ច

នាព្រឹកថ្ងៃអង្គារ ១៥រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ ឯកឧត្តម អគ្គនាយករង **នង ពិសិដ្ឋ** និងសហការី បានអនុញ្ញាតឱ្យថ្នាក់ដឹកនាំរបស់សមាគមអ្នកវាយតម្លៃនិងភ្នាក់ងារអចលនវត្ថុកម្ពុជា (CVEA) តំណាងដោយ **លោក សន សៀប** ប្រធានសមាគម **លោក ពឹង សេរី** អនុប្រធានសមាគម **លោក សួន សុលេញ** អគ្គលេខាធិការ និងសមាជិកក្រុមប្រឹក្សាភិបាល ចូលជួបសម្តែងការគួរសម។

នៅក្នុងកិច្ចជំនួបនេះ ឯកឧត្តមអគ្គនាយក **សុខ ដារ៉ា** បានចែករំលែកពីវឌ្ឍនភាពនៃកិច្ចដំណើរការអភិវឌ្ឍន៍នៃវិស័យបរធនបាលកិច្ច និងបានពិភាក្សាអំពីការបន្តពង្រឹងកិច្ចសហប្រតិបត្តិការរវាង **ន.ប.ធ.** និងសមាគម CVEA ក្នុងក្របខណ្ឌអនុស្សរណៈនៃការយោគយល់គ្នា (MoU) ដែលបានចុះហត្ថលេខា កាលពីថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២២។



រូបភាពកិច្ចជំនួបដើម្បីចែករំលែកពីវឌ្ឍនភាពនៃកិច្ចដំណើរការអភិវឌ្ឍន៍នៃវិស័យបរធនបាលកិច្ច។

## បេសកកម្មត្រួតពិនិត្យជាក់ស្តែងដល់ការដ្ឋានស្ថាបនាផ្លូវមួយខ្សែក្រោម MRD-PIU3 ប្រវែង ១៧.៥ គីឡូម៉ែត្រ

កាលពីថ្ងៃអង្គារ ១៥រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៣ និយ័តករបរធនបាលកិច្ច (**ន.ប.ធ**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាគទី១ (PIU1) ដឹកនាំ**ដោយ លោក ប៉ូ សំអាង** ប្រធានផ្នែកប្រតិបត្តិ មន្ត្រីជំនាញសមាជិក PIU1 ទីប្រឹក្សាគម្រោង និងអ្នកជំនាញការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) តំណាងដោយ Mrs. Xin Ren និង Mrs. Indah Setyawati ដោយមានការចូលរួមពីតំណាងក្រសួងអភិវឌ្ឍន៍ជនបទ (MRD-PIU3) ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ (MRD-PIU2) ធនាគារស្ថាបនា ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម អាជ្ញាធរមូលដ្ឋាននិងស្ថានប័នពាក់ព័ន្ធផ្សេងទៀត បានចុះបេសកកម្មត្រួតពិនិត្យជាក់ស្តែងដល់ការដ្ឋានស្ថាបនាផ្លូវមួយខ្សែក្រោម MRD-PIU3 ប្រវែង ១៧.៥ គីឡូម៉ែត្រ ស្ថិតនៅភូមិសំរោង ឃុំអូរម្លូរ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម និងបានចុះជួបសហគ្រាសផលិត និងកែច្នៃស្វាយចន្ទី (Cashew Nut Processing Enterprises) ស្ថិតនៅភូមិដីក្រហម ឃុំសំភាស ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដើម្បីពិនិត្យ និងវាយតម្លៃផលប៉ះពាល់បរិស្ថាន (ESMS) និងសុវត្ថិភាពសង្គម (Safeguard) របស់ក្រុមគោលដៅទទួលផល និងស្ថានភាពទីតាំងផ្លូវ មុនដំណើរការសាងសង់។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាពបេសកកម្មត្រួតពិនិត្យជាក់ស្តែងដល់ការដ្ឋានស្ថាបនាផ្លូវមួយខ្សែក្រោម MRD-PIU3 ប្រវែង ១៧.៥ គីឡូម៉ែត្រ។

## ពិធី "ប្រកាសពង្រីកការប្រើប្រាស់មុខងាររបស់ប្រព័ន្ធ FMIS, ការអនុវត្តនីតិវិធីតាមប្រព័ន្ធ FMIS ទាំងស្រុង, ការប្រើប្រាស់ប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី ១ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង ការដាក់ឱ្យអនុវត្តគម្រោងរៀបចំមុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅក្រសួងចំនួន ៥ដំបូង"

នារសៀលថ្ងៃពុធ ១កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ **ឯកឧត្តម ស៊ុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អម-ដោយឯកឧត្តមអគ្គនាយករង **ណី សាកល**, **លោក យុន វ៉ាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ និងមន្ត្រីជំនាញការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ បានចូលរួមពិធី "ប្រកាសពង្រីកការប្រើ-ប្រាស់មុខងាររបស់ប្រព័ន្ធ FMIS, ការអនុវត្តនីតិវិធីតាមប្រព័ន្ធ FMIS ទាំងស្រុង, ការប្រើប្រាស់ប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី ១ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងការដាក់ឱ្យអនុវត្តគម្រោងរៀបចំមុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅក្រសួងចំនួន ៥ដំបូង" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** នៅសាលាជាតិគយ។



រូបភាពពិធី "ប្រកាសពង្រីកការប្រើប្រាស់មុខងាររបស់ប្រព័ន្ធ FMIS, ការអនុវត្តនីតិវិធីតាមប្រព័ន្ធ FMIS ទាំងស្រុង, ការប្រើប្រាស់ប្រព័ន្ធឯកសារឌីជីថល (FMIS Portal) ជំនាន់ទី ១ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ និង ការដាក់ឱ្យអនុវត្តគម្រោងរៀបចំមុខងារគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅក្រសួងចំនួន ៥ដំបូង" ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## កិច្ចពិភាក្សាការងារជាមួយក្រុមប្រតិភូរបស់ក្រុមហ៊ុន Phillip Capital Group

នារសៀលថ្ងៃព្រហស្បតិ៍ ២កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ **ឯកឧត្តម ស៊ុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អម-ដោយ **ឯកឧត្តម ណី សាកល** អគ្គនាយករង, **លោក ហាយ សុវណ្ណា** ប្រធានស្ដីទីនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច និងមន្ត្រីជំនាញនៃ **ន.ប.ធ.** បានទទួលជួបពិភាក្សាការងារជាមួយក្រុមប្រតិភូរបស់ក្រុមហ៊ុន Phillip Capital Group ដឹកនាំដោយ **លោក LIM HUA MIN** ប្រធានក្រុមប្រឹក្សាភិបាលនៃ Phillip Capital Group ដោយមានការចូលរួមរបស់ **លោក Ong Teong Hoon** ប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ហ្វីលីព ត្រាស់ធី និង **លោក ព្រឿង សុភាព** ជាអ្នក-គ្រប់គ្រងទូទៅក្រុមហ៊ុន ហ្វីលីព ត្រាសធី នៅទីស្ដីការនៃ **ន.ប.ធ.**។

ភាគីទាំងពីរបានពិភាក្សាអំពីវឌ្ឍនភាព និងកាលានុវត្តភាពវិស័យបរធនបាលកិច្ចនៅកម្ពុជា ក៏ដូចជាបទពិសោធជោគជ័យអន្តរជាតិ ព្រមទាំងនិន្នាការនៃដំណើរការសេដ្ឋកិច្ចសកលផងដែរ។



រូបភាពកិច្ចពិភាក្សាការងារជាមួយក្រុមប្រតិភូរបស់ក្រុមហ៊ុន Phillip Capital Group។

## ពិធីចុះហត្ថលេខាលើកិច្ចសន្យា Trust Deed រវាងក្រុមហ៊ុន បេនចាវ៉ាន អ៊ែរសេត មេនេចមិន (ខេមបូឌា) ម.ក និងក្រុមហ៊ុន ស្រ្តងហ្វូល ត្រាសធី ឯ.ក

នាព្រឹកថ្ងៃចន្ទ ៦កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានអញ្ជើញចូលរួមជាមួយ **ឯកឧត្តម ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនិយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**) ជាអធិបតីក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យា Trust Deed រវាងក្រុមហ៊ុន បេនចាវ៉ាន អ៊ែរសេត មេនេចមិន (ខេមបូឌា) ម.ក និងក្រុមហ៊ុន ស្រ្តងហ្វូល ត្រាសធី ឯ.ក នៅអគារ Morgan Tower។



រូបភាពពិធីចុះហត្ថលេខាលើកិច្ចសន្យា Trust Deed រវាងក្រុមហ៊ុន បេនចាវ៉ាន អ៊ែរសេត មេនេចមិន (ខេមបូឌា) ម.ក និងក្រុមហ៊ុន ស្រ្តងហ្វូល ត្រាសធី ឯ.ក។

## កិច្ចប្រជុំដើម្បីត្រៀមបើកដាក់ឱ្យដំណើរការកម្មវិធីសវនកម្មឆ្នាំ២០២៣

នារសៀលថ្ងៃចន្ទ ៦កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំសហការីជួបប្រជុំជាមួយ **ឯកឧត្តម ឈុន សម្បត្តិ** ប្រធានអង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងសហការី ដើម្បីត្រៀមបើកដាក់ឱ្យដំណើរការកម្មវិធីសវនកម្មឆ្នាំ២០២៣។



រូបភាពកិច្ចប្រជុំដើម្បីត្រៀមបើកដាក់ឱ្យដំណើរការកម្មវិធីសវនកម្មឆ្នាំ២០២៣។

## កិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា

នាព្រឹកថ្ងៃអង្គារ ៧កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២៣ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), ជាសមាជិកក្រុមការងាររៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា និងជាអនុប្រធានក្រុមការងារបច្ចេកទេសទទួលបន្ទុកបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ បានដឹកនាំសហការី ចូលរួមកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា តាមប្រព័ន្ធអនឡាញ Zoom។




រូបភាពកិច្ចប្រជុំពិនិត្យ និងពិភាក្សាអំពីការរៀបចំសេចក្តីព្រាងគោលនយោបាយអភិវឌ្ឍវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា។

## សិក្ខាសាលាផ្សព្វផ្សាយ និងបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី "ដំណើរការ និងនីតិវិធីក្នុងការទទួលបានឥណទានក្រោមគម្រោង ACSEP សមាសភាគទី១"

នាថ្ងៃសុក្រ ១០កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ នៅខេត្តព្រះវិហារ និយ័តករបរធនបាលកិច្ច (**ន.ប.ធ**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សម្រាប់សមាសភាគទី១ (PIU1) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី "ដំណើរការ និងនីតិវិធីក្នុងការទទួលបានឥណទានក្រោមគម្រោង ACSEP សមាសភាគទី១" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម មុី វ៉ាន់** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) និងជានាយកគម្រោង ដោយមានការចូលរួមពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោង ACSEP សមាសភាគទី១, **ឯកឧត្តម អុឹង វណ្ណា** អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ និងជានាយកគម្រោង ACSEP សមាសភាគទី៣, **ឯកឧត្តម អ៊ុក គឹមសាន** អភិបាលរងនៃគណៈអភិបាលខេត្តព្រះវិហារ, លោកបណ្ឌិត Takeshi Ueda, សេដ្ឋវិទូផ្នែកធនធានធម្មជាតិ និងកសិកម្ម និងជាប្រធានក្រុមការងារ ADB ទទួលបន្ទុកគម្រោង ACSEP, និងលោកស្រី Hyunyoung Song, អ្នកជំនាញធនធានធម្មជាតិ និងកសិកម្ម និងជាសហប្រធានក្រុមការងាររវាង ADB និង ACSEP។

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្រោមកិច្ចសហការ និងសម្របសម្រួលពីរដ្ឋបាលខេត្តព្រះវិហារ ក្នុងគោលបំណងផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងអំពីគម្រោង ACSEP ពាក់ព័ន្ធនឹងដំណើរការ និងនីតិវិធីក្នុងការទទួលបានឥណទានបន្ថែម ដើម្បីពង្រីក និងពង្រឹងអាជីវកម្ម ដល់សហគ្រាសកសិ-ឧស្សាហកម្ម សហគមន៍កសិកម្ម និងកសិករចិញ្ចឹមមាន់ស្រុក ជាពិសេសសហគ្រាសផលិត ដែលមានបំណងស្វែងរកទុនបន្ថែមសម្រាប់គាំទ្រផែនការអាជីវកម្មរបស់ខ្លួន ដោយមានអ្នកចូលរួមមកពីតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងអភិវឌ្ឍន៍ជនបទ, រដ្ឋបាលមូលដ្ឋាន, ស្ថាប័នហិរញ្ញវត្ថុដៃគូ, សហគ្រាសកសិ-ឧស្សាហកម្ម, សហគមន៍កសិកម្ម ក៏ដូចជាកសិករចិញ្ចឹមមាន់ ដែលអញ្ជើញមកពីខេត្តព្រះវិហារ។

សូមបញ្ជាក់ថា គម្រោង ACSEP ត្រូវបានបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណង៖ ទី១).ជួយសម្រួលដល់ការទទួលបានឥណទានសម្រាប់សហគ្រាសកសិ-ឧស្សាហកម្ម និងសហគមន៍កសិកម្ម តាមរយៈធនាគារដៃគូទាំងពីរគឺ ARDB និង Sathapana ទី២).ជួយលើកកម្ពស់ទំនាក់ទំនងទីផ្សារក្នុងចំណោមសហគ្រាសកសិ-ឧស្សាហកម្ម និងសហគមន៍កសិកម្ម និងលើកកម្ពស់សុវត្ថិភាព និងគុណភាពម្ហូបអាហារ និងទី៣).ធ្វើអោយប្រសើរឡើងនូវការតភ្ជាប់បណ្តាញផ្លូវដឹកជញ្ជូនពីកសិដ្ឋានផលិតទៅកាន់ទីផ្សារ។




រូបភាពសិក្ខាសាលាផ្សព្វផ្សាយ និងបណ្តុះបណ្តាលពង្រឹងសមត្ថភាពស្តីពី "ដំណើរការ និងនីតិវិធីក្នុងការទទួលបានឥណទានក្រោមគម្រោង ACSEP សមាសភាគទី១" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) និងជានាយកគម្រោង។

## ពិធី "សម្ពោធអគារសិក្សាថ្មី នៅសាលាបឋមសិក្សា ជោគជ័យ"

នាព្រឹកថ្ងៃសុក្រ ១០កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ **ឯកឧត្តម ណី សាកល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ (**ន.ប.ធ.**) បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធី "សម្ពោធអគារសិក្សាថ្មី នៅសាលាបឋមសិក្សា ជោគជ័យ" ដែលរៀបចំឡើងដោយអង្គការមូលនិធិអេស៊ីលីដា-ចារឌីនសម្រាប់ការអប់រំ (AJF) នៅភូមិជោគជ័យ ឃុំសង្កែពីរ ស្រុកឆែប ខេត្តព្រះវិហារ។




រូបភាពពិធី "សម្ពោធអគារសិក្សាថ្មី នៅសាលាបឋមសិក្សា ជោគជ័យ"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888